ក្រសួងមហាផ្ទៃ

# នីតិវិធី
# បោះឆ្នោតជ្រើសរើស
# ប្រធានការិយាល័យប្រជាពលរដ្ឋ




បោះពុម្ពលើកទី២
ខែតុលា ឆ្នាំ២០១០

# នីតិវិធី
# នៃការបោះឆ្នោតជ្រើសរើស
# ប្រធានការិយាល័យប្រជាពលរដ្ឋ

បោះពុម្ពលើកទី២
ខែតុលា ឆ្នាំ ២០១០

# មាតិកា

សេចក្តីផ្តើម ......................................................................................១

**ក. ការរៀបចំគណៈកម្មាធិការបោះឆ្នោត**.......................................................២

ក.១ ការជ្រើសរើសតំណាងពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ.......................៣

ក.១.១ ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងពាណិជ្ជករ ..............៣

ក.១.២ ការបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករ ..........................៤

ក.២ ការជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ ៨

ក.២.១ ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងអង្គការ ..................៨

ក.២.២ ការបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល......៩

ក.៣ តួនាទី ភារកិច្ចរបស់គណៈកម្មាធិការបោះឆ្នោត .........................១២

ក.៤ របៀបរបបធ្វើការងាររបស់គណៈកម្មាធិការបោះឆ្នោត..................១២

**ខ. បែបបទ និងនីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ**....១៣

ខ.១ ការប្រជុំគណៈកម្មាធិការបោះឆ្នោត .........................................១៣

ខ.២ ការដាក់ស្នើបេក្ខជនឈរឈ្មោះបោះឆ្នោត...................................១៤

ខ.៣ ការពិនិត្យបេក្ខជនដាក់ស្នើ .....................................................១៥

ខ.៤ កិច្ចដំណើរការបោះឆ្នោត.........................................................១៦

ខ.៤.១ មុនប្រតិបត្តិការបោះឆ្នោត ...............................................១៦

ខ.៤.២ របៀបបោះឆ្នោត ...............................................................១៧

ខ.៤.៣ ការរាប់សន្លឹកឆ្នោត.............................................................១៨

ខ.៤.៤ សុពលភាពនៃសន្លឹកឆ្នោត ......................................................១៨

ខ.៤.៥ លទ្ធផលនៃការបោះឆ្នោត ......................................................១៩

ខ.៥ ការតែងតាំង ......................................................................................២០

**គ. ទម្រង់នានា** ......................................................................................................២១

**សេចក្តីណែនាំ** ..................................................................................................៣៣

# សេចក្តីផ្តើមនៃសេចក្តីណែនាំ
# ស្តីពី

ផ្អែកតាមសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពី ការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ ស្រុក ខណ្ឌ និងប្រកាសលេខ ៩២៧ ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋ នៅសាលាក្រុង សាលាស្រុក សាលាខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ បានតម្រូវឱ្យ បង្កើតការិយាល័យប្រជាពលរដ្ឋ។ ការិយាល័យប្រជាពលរដ្ឋ ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹតក្នុងការទទួលពាក្យបណ្តឹង ពីប្រជាពលរដ្ឋ ដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយ ពាក្យបណ្តឹងទាំងនោះ។ ការិយាល័យប្រជាពលរដ្ឋត្រូវមានប្រធានការិយាល័យមួយ(០១)រូប ដែលជាតំណាងអព្យាក្រឹតរបស់ប្រជា-ពលរដ្ឋ។ តំណាងប្រជាពលរដ្ឋនេះ ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយគណៈកម្មាធិការ បោះឆ្នោតមួយ។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋនេះ បានដំណើរការទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងមហាផ្ទៃ សូមធ្វើសេចក្តីណែនាំអំពីការរៀបចំគណៈកម្មាធិការបោះឆ្នោតជ្រើសរើស ប្រធានការិយាល័យប្រជាពលរដ្ឋ

និងនីតិវិធីនៃការបោះឆ្នោត ដែលជាបន្តទៅនេះហៅថាគណៈកម្មាធិការបោះឆ្នោត ដូចតទៅ :

## ក. អំពីការរៀបចំគណៈកម្មាធិការបោះឆ្នោត

គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ មានសមាសភាពដូចខាងក្រោមៈ

- ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ....................................ជាប្រធាន
- សមាជិកទាំងអស់ នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ..............ជាសមាជិក
- សមាជិកបី(០៣) រូប ជាតំណាងសហគមន៍ពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ ....................................................................................ជាសមាជិក
- សមាជិកបី(០៣)រូប ជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ ដែលបានចុះបញ្ជីត្រឹមត្រូវ ហើយដែលបានធ្វើសកម្មភាពក្នុងមូលដ្ឋានក្រុង ស្រុក ខណ្ឌ ..............................................................ជាសមាជិក ។

ការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានអោយគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

គណៈកម្មាធិការនេះ ត្រូវបង្កើតឡើងដោយដីការបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។ ដូចមានគំរូជូនភ្ជាប់មកជាមួយ ។

## ក.១ ការជ្រើសរើសតំណាងពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ

### ក.១.១ ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងពាណិជ្ជករ

ក្នុងការជ្រើសរើសនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញតំណាងពាណិជ្ជករតាមប្រភេទអាជីវកម្មទាំងអស់ដែលកំពុងប្រកបមុខរបរនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ។ ក្នុងការអញ្ជើញតំណាងពាណិជ្ជករត្រូវគិតគូរពីចំនួនសមស្របដោយកំណត់យកចំនួន ប្រមាណពី២០-៤០ នាក់នៃតំណាងពាណិជ្ជករដែលត្រូវចូលរួមស្តាប់ការផ្សព្វផ្សាយនេះ។ ចំពោះក្រុង ស្រុក ខណ្ឌណាដែលមានការបង្កើតជាក្រុម ឬសមាគម ឬ សហគមន៍ ឬសហករណ៍ ឬសហជីព... តាមប្រភេទអាជីវកម្មនីមួយៗ គួរអញ្ជើញតំណាងទាំងនោះមកចូលរួមតែម្តង។

ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាអធិបតីនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ តាមរបៀបវារៈសំខាន់ៗ ដូចខាងក្រោម :

- ការបង្ហាញដោយសង្ខេបអំពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រួមទាំងតួនាទីសំខាន់ៗរបស់ការិយាល័យទាំង-ពីរនេះ
- ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ សមាសភាព និងតួនាទីសំខាន់ៗរបស់ គណៈកម្មាធិការ
- នីតិវិធីបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមជាសមាជិករបស់ គណៈកម្មាធិការបោះឆ្នោត

- បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

ក្នុងកិច្ចប្រជុំខាងលើនេះ ត្រូវធ្វើការពិភាក្សាគ្នា ដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករ ដើម្បីចូលរួមជាសមាជិករបស់គណៈកម្មាធិការបោះឆ្នោត ។

## ក.១.២ ការបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករ

ក្នុងការបោះឆ្នោតនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌធ្វើការអញ្ជើញ តំណាងពាណិជ្ជករតាមប្រភេទអាជីវកម្ម ដែលបានអញ្ជើញឱ្យចូលរួមស្ដាប់ ការផ្សព្វផ្សាយស្ដីពីការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ដើម្បីចូលរួមបោះឆ្នោត ជ្រើសរើសតំណាងរបស់ខ្លួនឱ្យចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោត តាមកម្មវិធីដែលបានកំណត់ ។

ដូចបានបញ្ជាក់ជូនខាងលើ តំណាងពាណិជ្ជករដែលត្រូវជ្រើសរើសចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោតមានចំនួនបី (០៣) រូប។ ដើម្បីជ្រើសរើសបាននូវតំណាងទាំង០៣រូបនេះ ប្រធានក្រុមប្រឹក្សាដែលជាអធិបតីនៃកិច្ចប្រជុំត្រូវធ្វើការសម្របសម្រួលកំណត់អ្នកឈរឈ្មោះបោះឆ្នោតតាមជំរើសណាមួយដូចខាងក្រោម :

**ជម្រើសទី១:**

ត្រូវធ្វើការពិភាក្សា និងជំរុញលើកទឹកចិត្តដល់ពាណិជ្ជករទាំងអស់ដែលបានចូលរួមបោះឆ្នោតឱ្យស្ម័គ្រ ចិត្តឈរឈ្មោះជាបេក្ខជន យ៉ាងហោចណាស់ឱ្យបានចំនួន ៦ នាក់។ បន្ទាប់មកត្រូវធ្វើការកត់ឈ្មោះបេក្ខជន និងប្រភេទ អាជីវកម្មដើម្បីធ្វើការ

បោះឆ្នោត ។ វិធីសាស្ត្រកំណត់បេក្ខជនស្ម័គ្រចិត្តនេះអាចធ្វើឡើងតាមរយៈការលើកដៃ ឬការលើកសំនួរ បំផុសគំនិតនិងសាកសួរសមាជិកចូលរួមឱ្យកំណត់អ្នកដែលគួរឈរ ឈ្មោះជាបេក្ខជន ឬក៏វិធីសាស្ត្រផ្សេងទៀតដែលសមស្រប ។

**ជម្រើសទី២:**

តំណាងពាណិជ្ជករទាំងអស់ដែលបានចូលរួមបោះឆ្នោត គឺជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

កិច្ចប្រជុំបោះឆ្នោត ត្រូវស្ថិតក្រោមការសម្របសម្រួល និងដឹកនាំដោយប្រធានក្រុមប្រឹក្សា ហើយត្រូវធានាឱ្យមាន ការរៀបចំឧបករណ៍ សម្ភារៈចាំបាច់នានាសម្រាប់ដំណើរការបោះឆ្នោតដូចជា ប្រអប់ដាក់សន្លឹកឆ្នោត ក្រដាសបោះឆ្នោត ក្រដាសផ្ទាំងធំ ក៏ដូចជាការរក្សារបៀបរៀបរយនៃការបោះឆ្នោតជាដើម ។

សកម្មភាពសំខាន់ៗក្នុងដំណើរការបោះឆ្នោតរួមមាន :

- កត់ឈ្មោះបេក្ខជន ឬតំណាងពាណិជ្ជករទាំងអស់ដែលបានចូលរួមជាបេក្ខជនឈរឈ្មោះបោះឆ្នោតនៅ លើក្រដាសផ្ទាំងធំ ( ក្រដាសផ្ទាំងធំ) ដោយរៀបតាមលំដាប់លេខរៀង និងបិតលើជញ្ជាំង ឬក្តារខៀន ដើម្បីឱ្យអ្នកចូលរួមទាំងអស់អាចមើលឃើញច្បាស់ និងងាយស្រួលក្នុងការជ្រើសរើស ។ ទម្រង់សម្រាប់ កត់ត្រានេះមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ។
- មុននឹងចាប់ផ្តើមធ្វើការបោះឆ្នោត អ្នកសម្របសម្រួល ត្រូវធ្វើការរំលឹកឡើងវិញពីនីតិវិធីនៃការបោះឆ្នោតដូចជា ជ្រើសរើសយកតំណាងបីរូប ហើយសមាជិកនីមួយៗមានសិទ្ធិជ្រើសរើសតំណាងពាណិជ្ជករ ចំនួនបីរូបដែលខ្លួនពេញចិត្តជាដើម ។

- អ្នកសម្របសម្រួល ធ្វើការណែនាំដល់អ្នកចូលរួមពីការជ្រើសរើសតំណាងពាណិជ្ជករចំនួនបីរូប ដែលខ្លួនពេញចិត្តដោយសរសេរឱ្យបានច្បាស់លាស់ :
  - សរសេរលេខរៀងបេក្ខជនដូចមានក្នុងក្រដាសផ្ទាំងធំដែលបិតនៅលើជញ្ជាំង ឬក្តារខៀន ឬ
  - សរសេរឈ្មោះបេក្ខជន ឬ
  - សរសេរលេខរៀង និងឈ្មោះបេក្ខជន ។

ក្នុងការជ្រើសរើសនេះ អ្នកសម្របសម្រួលត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ដល់អ្នកចូលរួមទាំងអស់ ដើម្បីធ្វើការពិចារណា និងសម្រេចចិត្ត និងធានាថា ជាការបោះឆ្នោតសម្ងាត់ និងប្រកបដោយតម្លាភាព ។

- បន្ទាប់មកអ្នកសម្របសម្រួល ត្រូវអញ្ជើញអ្នកចូលរួមទាំងអស់ (ម្តងម្នាក់) មកទទួលយកសន្លឹកឆ្នោត និងធ្វើការបោះឆ្នោតនៅទីតាំងមួយដែលបានរៀបចំដាច់ដោយឡែក ដើម្បីធានាភាពសម្ងាត់ (បន្ទប់បោះឆ្នោត ឬ ទីតាំងសមស្របសម្រាប់គូសសន្លឹកឆ្នោត) ។ សន្លឹកឆ្នោត ដែលបានគូសរួចហើយត្រូវយកទៅដាក់នៅក្នុងហិបឆ្នោតដែលនៅក្បែរនោះ រួចត្រឡប់មកអង្គុយនៅកន្លែងវិញ ដើម្បីរង់ចាំស្តាប់លទ្ធផល។ សន្លឹកឆ្នោតត្រូវប្រើក្រដាសពណ៌ស ដែលមាន ទំហំសមស្របដូចគ្នា និងមានបោះត្រា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។
- អ្នកសម្របសម្រួល ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតភ្លាមដោយធ្វើការរាប់សន្លឹកឆ្នោត ម្តងមួយសន្លឹកនៅមុខអ្នកចូលរួមទាំងអស់ និងធ្វើការបូកសរុបសម្លេងគាំទ្រ របស់តំណាងពាណិជ្ជករ នីមួយៗ។

បន្ទាប់មក ត្រូវធ្វើចំណាត់ថ្នាក់បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេលំដាប់ទី១ លំដាប់ទី២ និងលំដាប់ទី៣ ដើម្បីជ្រើសរើសជាតំណាងពាណិជ្ជករដែលត្រូវចូលរួមក្នុងគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីមានសម្លេងគាំទ្រស្មើគ្នា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមៈ

- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី បេក្ខជនជា ស្ត្រីត្រូវជាប់ឆ្នោត។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងច្រើននាក់ជាស្ត្រី ប្រធានក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាមក្នុងចំណោមបេក្ខជនជាស្ត្រីដែលមានសម្លេងស្មើគ្នានោះ។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះសុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី ប្រធានក្រុមប្រឹក្សាត្រូវ រៀបចំការបោះឆ្នោតភ្លាមជាលើកទី២ ឬលើកទី៣... ជាបន្តបន្ទាប់ ដោយយកតំណាងបេក្ខជនដែលមានសម្លេងស្មើគ្នានោះមកធ្វើការបោះឆ្នោត និងប្រើប្រាស់នីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ។

- នៅចុងបញ្ចប់នៃការបោះឆ្នោត ប្រធានក្រុមប្រឹក្សា ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោត និងប្រកាសអំពីឈ្មោះបេក្ខជន ដែលបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន។ ប្រធានក្រុមប្រឹក្សាក៏ត្រូវធានាថា របាយការណ៍អំពីលទ្ធផលនៃការបោះឆ្នោតនោះ បានរៀបចំត្រឹមត្រូវ និងច្បាស់លាស់ ។

## ក.២ ការជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ

### ក.២.១ ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល

ក្នុងការជ្រើសរើសនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញប្រធានអង្គការមិនមែនរដ្ឋាភិបាល ទាំងអស់ដែលធ្វើមានមូលដ្ឋាន និងធ្វើសកម្មភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការ ជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ។

ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាអធិបតីនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ តាមរបៀបវារៈសំខាន់ៗដូចខាងក្រោម ៈ

- ការបង្ហាញដោយសង្ខេបអំពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រួមទាំងតួនាទីសំខាន់ៗរបស់ការិយាល័យទាំងពីរនេះ
- ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋសមាសភាព និងតួនាទីសំខាន់ៗរបស់គណៈកម្មាធិការ
- នីតិវិធីបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមជា សមាជិករបស់គណៈកម្មាធិការបោះឆ្នោត
- បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើស ប្រធានការិយាល័យប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ អធិបតីនៃកិច្ចប្រជុំ ត្រូវធ្វើការពិភាក្សាគ្នាដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល ដើម្បី

ចូលរួមជាសមាជិករបស់ គណៈកម្មាធិការបោះឆ្នោត ។

## ក.២.២ ការបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល

ក្នុងការបោះឆ្នោតនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញប្រធានអង្គការមិនមែនរដ្ឋាភិបាល ទាំងអស់ដែលមាន ទីតាំងនៅក្នុងខេត្ត និងធ្វើសកម្មភាពនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅមកចូលរួម បោះឆ្នោតជ្រើសរើស តំណាងរបស់ខ្លួន ចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោតតាមកម្មវិធីដែលបានកំណត់ ។ ដូចបានបញ្ជាក់ជូនខាងលើ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវជ្រើសរើសចូលជា សមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានមានចំនួន ០៣រូប ហើយអង្គការនីមួយៗមានសិទ្ធិស្មើគ្នាក្នុងការឈរឈ្មោះបោះឆ្នោត ។

កិច្ចប្រជុំបោះឆ្នោត ត្រូវស្ថិតក្រោមការសម្របសម្រួល និងដឹកនាំដោយប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយត្រូវធានាឱ្យមានការរៀបចំឧបករណ៍សម្ភារៈចាំបាច់នានាសម្រាប់ដំណើរការបោះឆ្នោតដូចជា ប្រអប់ដាក់សន្លឹកឆ្នោតក្រដាសបោះឆ្នោត ក្រដាសផ្ទាំងធំ ក៏ដូចជាការរក្សារបៀបរៀបរយនៃការបោះឆ្នោតជាដើម ។

សកម្មភាពសំខាន់ៗក្នុងដំណើរការបោះឆ្នោតរួមមាន :

- កត់ឈ្មោះអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចូលរួមបោះឆ្នោតនៅលើក្រដាសផ្ទាំងធំ ដោយរៀបតាមលំដាប់លេខរៀង និងបិតលើជញ្ជាំងឬក្តារខៀន ដើម្បីឱ្យអ្នកចូលរួមទាំង អស់អាចមើលឃើញច្បាស់ និងងាយស្រួលក្នុងការជ្រើសរើស ។ ទម្រង់សម្រាប់កត់ត្រានេះមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

- មុននឹងចាប់ផ្តើមធ្វើការបោះឆ្នោត អ្នកសម្របសម្រួល ត្រូវធ្វើការរំលឹកឡើងវិញ ពីនីតិវិធីនៃការបោះឆ្នោតដូចជា ជ្រើសរើសយកតំណាងបី (០៣)រូប ហើយសមាជិកនីមួយៗមានសិទ្ធិជ្រើសរើសអង្គការចំនួនបី ដែលខ្លួនពេញចិត្តជាដើម។
- អ្នកសម្របសម្រួល ធ្វើការណែនាំដល់អ្នកចូលរួមពីការជ្រើសរើសតំណាងអង្គការចំនួនបី(០៣)ដែលខ្លួនពេញចិត្ត ដោយសរសេរឱ្យបានច្បាស់លាស់ :
    - សរសេរលេខរៀងរបស់អង្គការដូចមាននៅក្នុងក្រដាសផ្ទាំងធំដែលបិតនៅលើជញ្ជាំង ឬ ក្តារខៀន ឬ
    - សរសេរឈ្មោះតំណាងអង្គការ ឬ
    - សរសេរតែឈ្មោះអង្គការ ឬ
    - សរសេរលេខរៀង ឈ្មោះតំណាងអង្គការ និងឈ្មោះអង្គការ ។

    ក្នុងការជ្រើសរើសនេះ អ្នកសម្របសម្រួលត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ដល់អ្នកចូលរួមទាំងអស់ ដើម្បីធ្វើការពិចារណា និងសម្រេចចិត្ត និងធានាថាជាការបោះឆ្នោតសម្ងាត់ និងប្រកបដោយតម្លាភាព។
- បន្ទាប់មក អ្នកសម្របសម្រួល ត្រូវអញ្ជើញអ្នកចូលរួមទាំងអស់(ម្តងម្នាក់) មកទទួលយកសន្លឹកឆ្នោត និងធ្វើការបោះឆ្នោតនៅបន្ទប់គូសសន្លឹកបោះឆ្នោត ឬ ទីតាំងសមស្របសម្រាប់គូសសន្លឹកឆ្នោត ដើម្បីធានាភាពសម្ងាត់។ សន្លឹកឆ្នោតដែលបានគូសរួចហើយ ត្រូវយកទៅដាក់នៅក្នុងហិបឆ្នោតដែលនៅក្បែរនោះ រួចត្រឡប់មក អង្គុយនៅកន្លែងវិញ ដើម្បីរង់ចាំស្តាប់

លទ្ធផល ។ សន្លឹកឆ្នោតត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំសមស្រប ដូចគ្នា និងមានបោះត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

- អ្នកសម្របសម្រួល ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតភ្លាម ដោយធ្វើការរាប់សន្លឹកឆ្នោត ម្តងមួយសន្លឹកៗនៅមុខអ្នកចូលរួមទាំងអស់ និងបូកសរុបសម្លេងគាំទ្ររបស់អង្គការនីមួយៗ ។ បន្ទាប់មកត្រូវធ្វើចំណាត់ថ្នាក់អង្គការដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេលំដាប់ទី១ លំដាប់ទី២ និងលំដាប់ទី៣ ដើម្បីជ្រើសរើសជាតំណាងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងគណៈកម្មាធិការបោះឆ្នោត ។ ក្នុងករណីមានសម្លេងគាំទ្រស្មើគ្នា ប្រធានក្រុមប្រឹក្សាត្រូវ រៀបចំការបោះឆ្នោតភ្លាមជាលើកទី២ ឬលើកទី៣... ជាបន្តបន្ទាប់ ដោយយកតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលមានសម្លេងស្មើគ្នានោះមកធ្វើការបោះឆ្នោត និងប្រើប្រាស់នីតិវិធីដូចបានអនុវត្តនៅលើកទី១ ដែរ ។
- នៅចុងបញ្ចប់នៃការបោះឆ្នោត អធិបតីនៃកិច្ចប្រជុំ ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោត និង ប្រកាសឈ្មោះអង្គការដែលបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបោះឆ្នោត ។ ប្រធានក្រុមប្រឹក្សាត្រូវធានាថារបាយការណ៍លទ្ធផលនៃការបោះឆ្នោតនោះ បានរៀបចំត្រឹមត្រូវ និងច្បាស់លាស់ ។

បន្ទាប់ពីជ្រើសរើសបានតំណាងពាណិជ្ជករ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំដីកា ស្តីពីការបង្កើតគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

ដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខាតាមទម្រង់ដូចមានជូន ភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

នៅក្នុងអាណត្តិបំពេញការងាររបស់ខ្លួន ក្នុងករណីមានតំណាងសហគមន៍ពាណិជ្ជករ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាលណាមួយក្នុងចំណោមតំណាងទាំងបី (០៣)រូប នៅក្នុងគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន លាឈប់ពីការងារ ឬទទួលមរណភាព តំណាងបំរុងដែលមានលេខរៀងបន្ទាប់ ត្រូវចូលបំពេញការងារជំនួសដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចេញដីកាទទួលស្គាល់សមាសភាពថ្មីនេះជាផ្លូវការជាថ្មី។

## ក.៣ តួនាទី ភារកិច្ចរបស់គណៈកម្មាធិការបោះឆ្នោត

គណៈកម្មាធិការបោះឆ្នោត មានភារកិច្ច :

- រៀបចំការប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- រៀបចំសន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- ប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- លើកសំណើជូនក្រុមប្រឹក្សាពិនិត្យ និងទទួលស្គាល់បេក្ខជនជាប់ឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ
- ពិនិត្យ តាមដានការអនុវត្តសកម្មភាពរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ

## ក.៤ របៀបរបបធ្វើការងាររបស់គណៈកម្មាធិការបោះឆ្នោត

គណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន អាចរៀបចំកិច្ចប្រជុំរបស់ខ្លួនទៅតាមការចាំបាច់ តាមសំណើរបស់ប្រធានគណៈកម្មាធិការ ឬក្រុមប្រឹក្សាក្រុង ស្រុក

ខណ្ឌ ឬតាមសំណើយ៉ាងតិចមួយភាគបីនៃសមាជិកគណៈកម្មាធិការមូលដ្ឋាន។ ការិយាល័យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវជួយប្រធានគណៈកម្មាធិការក្នុងការរៀបចំរាល់កិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការ។

## ៦. បែបបទ និងនីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

គណៈកម្មាធិការបោះឆ្នោត ត្រូវបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ តាមនីតិវិធីដូចខាងក្រោម៖

- កោះប្រជុំគណៈកម្មាធិការបោះឆ្នោត
- ដាក់ស្នើបេក្ខជនឈរឈ្មោះបោះឆ្នោត
- ពិនិត្យអំពីការដាក់ស្នើបេក្ខជន និងការរៀបចំសន្លឹកឆ្នោត
- កិច្ចដំណើរការបោះឆ្នោត
- ដីកាតែងតាំង

### ៦.១ ការប្រជុំគណៈកម្មាធិការបោះឆ្នោត

ក្រោយពេលបង្កើតបានគណៈកម្មាធិការបោះឆ្នោត យ៉ាងយូរប្រាំពីរ(០៧)ថ្ងៃ គណៈកម្មាធិការនេះ ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បី៖

- ប្រកាសសមាភាពគណៈកម្មាធិការបោះឆ្នោត
- ផ្សព្វផ្សាយអំពីសេចក្តីណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- ណែនាំអំពីនីតិវិធីនៃការដាក់ស្នើបេក្ខភាពសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោត

- កំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

ការិយាល័យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំនេះ និងត្រូវរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនេះ។

## ៦.២ ការដាក់ស្នើបេក្ខជនឈរឈ្មោះបោះឆ្នោត

សមាជិកគ្រប់រូប នៃគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានជ្រើសរើសតំណាងប្រជាពលរដ្ឋ មានសិទ្ធិឧទ្ទេសនាម បេក្ខជនយ៉ាងច្រើនពីរ (០២) រូបសម្រាប់ជាបេក្ខជនឈរបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ។ បេក្ខជនទាំងនោះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចតទៅ :

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី ៣៥ ឆ្នាំ ដល់ ៦០ ឆ្នាំ
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងក្រុង ស្រុក ខណ្ឌ ដែលសាមីជនមានបំណងឈរឈ្មោះ
- មានបទពិសោធន៍ការងាររដ្ឋបាល សង្គមស៊ីវិល ឬផ្នែកឯកជន ចាប់ពី ០៥ ឆ្នាំឡើងទៅ
- មានកំរិតវប្បធម៌ចាប់ពីមធ្យមសិក្សាបឋមភូមិ ឬសញ្ញាប័ត្រមានតម្លៃស្មើ
- បេក្ខជនមិនត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធដឹកនាំណាមួយរបស់គណបក្សនយោបាយណាមួយ ឬជាបេក្ខជន របស់គណបក្សនយោបាយណាមួយ។

**បេក្ខជនដែលគ្មានសិទ្ធិឈរឈ្មោះបោះឆ្នោត:**

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយុទ្ធពលខេមរភូមិន្ទ នគរបាលជាតិ

ក្នុងមុខតំណែង

- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់
- ព្រះសង្ឃ ឬបព្វជិតសាសនា
- ជនដែលតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ។

ក្នុងការដាក់ស្នើបេក្ខភាពបេក្ខជននេះ សមាជិកគណៈកម្មាធិការគ្រប់រូប ត្រូវធ្វើលិខិតស្នើសុំដាក់បេក្ខជន ទាំងនោះទៅប្រធានគណៈកម្មាធិការបោះឆ្នោតរៀងៗខ្លួន ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបរបស់បេក្ខជននោះដូច មានគំរូប្រវត្តិរូបសង្ខេបជូនភ្ជាប់មកជាមួយ ។ ក្នុងការដាក់ស្នើបេក្ខជនទាំងពីររូបនេះ ត្រូវមានបេក្ខជនជាស្ត្រីមួយរូប ។

គណៈកម្មាធិការ ត្រូវកំណត់កាលបរិច្ឆេទឱ្យបានច្បាស់លាស់អំពីពេលវេលានៃការចាប់ផ្តើមដាក់ស្នើបេក្ខជន និង កាលបរិច្ឆេទចុងក្រោយ ។ កាលបរិច្ឆេទចាប់ផ្តើមដាក់បេក្ខភាព ត្រូវចាប់ផ្តើមពីថ្ងៃបន្ទាប់ពីកិច្ចប្រជុំនេះ ហើយត្រូវបញ្ចប់យ៉ាងយូរ ១៤ថ្ងៃ បន្ទាប់ពីថ្ងៃចាប់ផ្តើម ។

## ៩.៣ ការពិនិត្យបេក្ខជនដាក់ស្នើ

នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវជួយដល់ប្រធានគណៈកម្មាធិការក្នុងការពិនិត្យលើបេក្ខភាព ដែលបានដាក់ស្នើ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយលក្ខណសម្បត្តិបេក្ខជនដែលបានកំណត់ក្នុងចំនុច ៩.២ នៃសេចក្តីណែនាំនេះរួចហើយ ត្រូវលើកយោបល់ជូនប្រធានគណៈកម្មាធិការដើម្បីពិនិត្យ និងសម្រេច ។

ក្នុងករណីដែលពិនិត្យឃើញថាមានបេក្ខជនណាមួយ ពុំមានលក្ខណៈសម្បត្តិសមស្របតាមការកំណត់ខាងលើនេះទេ ប្រធានគណៈកម្មាធិការត្រូវធ្វើលិខិតជូន

ដំណឹងទៅសមាជិកគណៈកម្មាធិការដែលបានដាក់ស្នើនោះវិញ ដើម្បីជូនជ្រាបជាព័ត៌មាន។

នៅពេលដល់កាលកំណត់ចុងក្រោយហើយ បើមានការដាក់ស្នើតែបេក្ខជនតិចជាងបីរូប នោះប្រធានគណៈកម្មាធិការ ត្រូវស្នើអោយសមាជិកដែលដាក់ស្នើនោះធ្វើការដាក់ស្នើបេក្ខជនបន្ថែម ឬប្រធានឧទ្ទេសនាមបេក្ខជនបន្ថែមក៏បាន។

ក្រោយពីការពិនិត្យ សម្រេចរបស់ប្រធានគណៈកម្មាធិការរួចហើយប្រធានក្រុមប្រឹក្សាត្រូវចាត់ឱ្យ នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ រៀបចំសន្លឹកឆ្នោតទៅតាមចំនួនសមាជិកគណៈកម្មាធិការបោះឆ្នោត។

**សន្លឹកឆ្នោតនីមួយៗត្រូវ:**

- ប្រើក្រដាសពណ៌ស ដែលមានទម្រង់ ទំហំដូចគ្នា ដោយសរសេរឈ្មោះបេក្ខជន ទៅតាមលំដាប់អក្សរ នៃឈ្មោះរបស់បេក្ខជន (សរសេរដោយដៃ ឬម៉ាស៊ីនអង្គុលីលេខ ឬកុំព្យូទ័រ)។
- រៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន
- មានត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត។ (ដូចមានគំរូសន្លឹកឆ្នោតជូនភ្ជាប់មកជាមួយ)។

## ៩.៤ កិច្ចដំណើរការបោះឆ្នោត

### ៩.៤.១ មុនប្រតិបត្តិការបោះឆ្នោត

ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវពិនិត្យមើលអំពីកូរ៉ុម (ដោយមានវត្តមានលើសពីពាក់កណ្ដាលនៃចំនួន សមាជិកសរុបរបស់គណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន ទើបចាត់ទុកជាបានការ) និងជំរាបជូនអង្គប្រជុំអំពីគោលការណ៍សំខាន់ៗ

ដូចខាងក្រោមៈ

- នីតិវិធីនៃការបោះឆ្នោត
- បង្ហាញ និងណែនាំអំពីលក្ខណៈនៃសន្លឹកឆ្នោត
- របៀបគូសសន្លឹកឆ្នោត
- អានឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជូនអង្គប្រជុំបោះឆ្នោត

កាិរិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ដែលជាលេខាធិការដ្ឋានគណៈកម្មាធិការបោះឆ្នោត មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំ និងចុះបញ្ជីវត្តមានសមាជិកគណៈកម្មាធិការបោះឆ្នោត
- រៀបចំបញ្ជីឈ្មោះបេក្ខជននៅលើក្រដាសផ្ទាំងធំ (ហ្វ្លីបឆាត) ដើម្បីត្រៀមសម្រាប់កត់ត្រាលទ្ធផលបោះឆ្នោត
- ចែកជូនសន្លឹកឆ្នោតទៅសមាជិកគណៈកម្មាធិការបោះឆ្នោត
- រាប់លទ្ធផលបោះឆ្នោត
- ធ្វើកំណត់ហេតុកិច្ចប្រជុំ
- ការងារមួយចំនួនទៀត តាមការចាំបាច់។

## ៦.៤.២ របៀបបោះឆ្នោតៈ

- មានតែសមាជិកគណៈកម្មាធិការបោះឆ្នោតទេ ទើបមានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- សមាជិកគណៈកម្មាធិការបោះឆ្នោតគ្រប់រូបដែលមានវត្តមាន នឹងត្រូវបានចែកជូននូវសន្លឹកឆ្នោត មួយសន្លឹក
- អ្នកបោះឆ្នោតមួយរូបៗ ត្រូវគូសសញ្ញា "✓" នៅលើសន្លឹកឆ្នោតត្រង់ប្រអប់

"ការបោះឆ្នោតគាំទ្រ" នៅជួរបន្ទាត់ខាងស្តាំនៃឈ្មោះបេក្ខជនចំនួនមួយ (០១)រូប ដែលខ្លួនគាំទ្រ រួចយកទៅដាក់នៅក្នុងហិបឆ្នោតបិទជិតមួយ ដែលនៅក្បែរនោះ

### ៦.៤.៣ ការរាប់សន្លឹកឆ្នោត

លេខាធិការដ្ឋាននៃគណៈកម្មាធិការ ត្រូវបើកហិបឆ្នោត យកសន្លឹកឆ្នោតមករាប់ដោយផ្ទៀងផ្ទាត់ជាមួយ វត្តមានរបស់សមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានដែលបានចូលរួម។ បន្ទាប់មក ត្រូវបើកសន្លឹកឆ្នោតម្តងមួយសន្លឹកៗ ដើម្បីពិនិត្យ និងត្រូវកត់ត្រាលទ្ធផលនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំដែលមានសរសេរឈ្មោះបេក្ខជនដូចមានក្នុងសន្លឹកឆ្នោត រួចហើយធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតនោះ។

### ៦.៤.៤ សុពលភាពនៃសន្លឹកឆ្នោត

សន្លឹកឆ្នោត ដែលត្រូវបានទទួលស្គាល់ថាបានការ ត្រូវតែជាសន្លឹកឆ្នោតដែលៈ

- រក្សានូវទ្រង់ទ្រាយដូចដើមរបស់សន្លឹកឆ្នោត
- មានគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងស្តាំចំពោះបេក្ខជនដែលខ្លួនគាំទ្រ

**សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែលៈ**

- មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូន
- គ្មានត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គូសគាំទ្របេក្ខជនលើសពីមួយនាក់
- មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
- មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត

- រហែក ឬខូច
- មានគំនូសដែលមិនអាចកំណត់បានថា ជាគាំទ្រដល់បេក្ខជនណាមួយ ។

## ៩.៩.៥ លទ្ធផលនៃការបោះឆ្នោត

ក្រោយពេលការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ជាស្ថាពរ លេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន ត្រូវរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការបោះឆ្នោតនេះ ។ បន្ទាប់មក ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតភ្លាម ។ បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ គឺជាបេក្ខជនជាប់ឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ ។

ក្នុងករណីមានបេក្ខជនចាប់ពីពីរ(០២)រូប ទទួលបានសម្លេងគាំទ្រច្រើនជាងគេស្មើគ្នាត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម :

- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី បេក្ខជនជាស្ត្រីត្រូវជាប់ឆ្នោត ។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងច្រើននាក់ជាស្ត្រី ប្រធានគណៈកម្មាធិការត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាម ក្នុងចំណោមបេក្ខជនជាស្ត្រីដែលមានសម្លេងស្មើគ្នានោះ តាមនីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ ។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះសុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី ប្រធានគណៈកម្មាធិការ ត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាមក្នុងចំណោមបេក្ខជនដែលមានសម្លេងស្មើគ្នានោះ តាមនីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ ។

ប្រសិនបើការបោះឆ្នោតលើកទី២នេះ នៅតែទទួលបានសម្លេងគាំទ្រស្មើគ្នាទៀត សម្លេងប្រធានគណៈកម្មាធិការមានឧត្តមានុភាព។

## ៩.៥ ការតែងតាំង

បន្ទាប់ពីការប្រកាសលទ្ធផលរបស់ប្រធានគណៈកម្មាធិការបោះឆ្នោតរួចហើយប្រធានគណៈកម្មាធិការត្រូវធ្វើសំណើ ទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសាមីដើម្បីដាក់ចេញនូវដីកាតែងតាំងដូចមានគំរូជូនភ្ជាប់មកជាមួយ និងរៀបចំចុះកិច្ចសន្យាជាមួយបេក្ខជនជាប់ឆ្នោតនេះ។ សំណើត្រូវភ្ជាប់មកជាមួយនូវកំណត់ហេតុនៃកិច្ចប្រជុំ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំសេចក្តីព្រាង ដីកាស្តីពីការតែងតាំងនេះ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា។

# ឧបសម្ព័ន្ធ

## ខ្រម្ងទនានា

## បញ្ជីឈ្មោះបេក្ខជនតំណាងពាណិជ្ជករចូលរួមបោះឆ្នោត

| ល.រ | នាម-គោត្តនាម | ប្រភេទអាជីវកម្ម | សម្លេងគាំទ្រ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |

## បញ្ជីឈ្មោះបេក្ខជនតំណាងអង្គការចូលរួមបោះឆ្នោត

| ល.រ | នាម-គោត្តនាម | តំណាងអង្គការ | សម្លេងគាំទ្រ | សរុប | សម្គាល់ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ.............................................................ជាសមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន ជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ នៃក្រុង ស្រុក ខណ្ឌ...................................................................

**<u>សូមគោរពជូន</u>**
**លោក លោកស្រី ប្រធានគណៈកម្មាធិការបោះឆ្នោត**

**កម្មវត្ថុ :** សំណើសុំដាក់បេក្ខជនឈរឈ្មោះបោះឆ្នោត ជាប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ.................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ មានកិត្តិយសសូមគោរពជូនលោក លោកស្រីប្រធានគណៈកម្មាធិការបោះឆ្នោតមេត្តាជ្រាបថា: លោក លោកស្រី ដែលមានឈ្មោះខាងក្រោមនេះ ពិតជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ :

១- ..............................(ឈ្មោះ).......................ភេទ.................អាយុ....................ឆ្នាំ

២- ..............................(ឈ្មោះ).......................ភេទ.................អាយុ....................ឆ្នាំ

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីប្រធានគណៈកម្មាធិការបោះឆ្នោត មេត្តាពិនិត្យ និងចុះឈ្មោះបេក្ខជនដែលដាក់ស្នើខាងលើក្នុងបញ្ជីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ដោយសេចក្តីអនុគ្រោះ ។

សូមលោក លោកស្រីប្រធានគណៈកម្មាធិការបោះឆ្នោត មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ នាងខ្ញុំ។

ថ្ងៃទី............ខែ.............ឆ្នាំ..................

**អ្នកស្នើ**

(ហត្ថលេខា និងឈ្មោះ)

បានទទួល

នៅថ្ងៃទី..........ខែ...............ឆ្នាំ.............

វេលាម៉ោង...................។

**អ្នកទទួល**

(ហត្ថលេខា និងឈ្មោះ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត :...............................

ក្រុង ស្រុក :.......................

លេខ:...............................

# ដីកា

# ស្តីពី

# ការបង្កើតគណៈកម្មាធិការបោះឆ្នោត ជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

*******

## ក្រុមប្រឹក្សាក្រុង ស្រុក...............

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ....................ចុះថ្ងៃទី..........ខែ................ឆ្នាំ.........................ស្តីពីការទទួលស្គាល់ក្រុមប្រឹក្សាក្រុង ស្រុក..........................................
- យោងសេចក្តីសម្រេចលេខ១២ស.ស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ
- យោងប្រកាសលេខ ៩២៧ប្រ.ក ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅ
- សេចក្តីណែនាំលេខ......................ចុះថ្ងៃទី.........ខែ............ឆ្នាំ...................ស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- យោងតាមលទ្ធផលនៃការបោះឆ្នោតនាថ្ងៃទី..........ខែ............ឆ្នាំ...................

# សម្រេច

## ប្រការ១.

បង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ដែលមានសមាសភាពដូច ខាងក្រោម:

១- ..........(ឈ្មោះ)........... ជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ.......................... ជាប្រធាន

២- ..........(ឈ្មោះ).......................(តួនាទី).....................................................ជាសមាជិក

៣- ..........(ឈ្មោះ).......................(តួនាទី).....................................................ជាសមាជិក

**ប្រការ២.**

គណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន មានភារកិច្ច ÷

- រៀបចំការប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- រៀបចំសន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- ប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- លើកសំណើជូនក្រុមប្រឹក្សាពិនិត្យ និងទទួលស្គាល់បេក្ខជនជាប់ឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ
- ពិនិត្យ តាមដានសកម្មភាពរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ

**ប្រការ៣.**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំនាយករដ្ឋបាល និងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ស្រុក ខណ្ឌ ក្នុងការជួយកិច្ចការរបស់គណៈកម្មាធិការបោះឆ្នោតតាមការចាំបាច់។

**ប្រការ៤.**

ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអស់លោក លោកស្រីដូចមានឈ្មោះក្នុងប្រការ១ ខាងលើ នេះ ត្រូវអនុវត្តដីកានេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃទី..........ខែ..............ឆ្នាំ................

**ប្រធានក្រុមប្រឹក្សា**

(ហត្ថលេខា)

(ត្រា)

(ឈ្មោះ)

**កន្លែងផ្ញើ** *(printed heading: ចំលងជូន)*

- *ក្រសួងមហាផ្ទៃ*
- *ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ*
- *សាលាខេត្ត........................*
- *សាលាឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ*
  *( ដើម្បីជូនជ្រាប )*
- *ដូចក្នុងប្រការ១ និងប្រការ៤ ( ដើម្បីអនុវត្ត )*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត :...............................

ក្រុង ស្រុក :.......................

លេខ:...............................

# ដីកា

# ស្តីពី

# ការតែងតាំងប្រធានការិយាល័យប្រជាពលរដ្ឋ

*******

## ក្រុមប្រឹក្សាក្រុង ស្រុក................

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ..............ចុះថ្ងៃទី........ខែ.............ឆ្នាំ................ស្តីពីការទទួលស្គាល់ក្រុមប្រឹក្សាក្រុង ស្រុក.......................
- យោងសេចក្តីសម្រេចលេខ១២ស.ស.រ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ
- យោងប្រកាសលេខ ៩២៧ប្រ.ក ចុះថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅ
- យោងសេចក្តីកំណត់លេខ................ចុះថ្ងៃទី.........ខែ..................ឆ្នាំ...........ស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ
- យោងតាមកំណត់ហេតុ ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ របស់គណៈកម្មាធិការបោះឆ្នោតចុះថ្ងៃទី...........ខែ..............ឆ្នាំ...............

# សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំង...............លោក ឬ លោកស្រី ឬ កញ្ញា................ ជាប្រធានការិយាល័យប្រជាពលរដ្ឋប្រចាំនៅក្រុង ស្រុក ខណ្ឌ..............................។

**ប្រការ២.**

ប្រធានការិយាល័យប្រជាពលរដ្ឋ មានតួនាទី និងមុខងារដូចខាងក្រោម ÷

**តួនាទី :**

ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹតក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ អំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ាទាំងនោះ។

**មុខងារ :**

- ធានាថា បញ្ហានានារបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយដោយមន្ត្រីរាជការ បុគ្គលិករបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ស្របតាមលក្ខណៈច្បាប់ លិខិតបទដ្ឋាននានាដោយគ្មានបែបបទរដ្ឋបាលច្រើន និងគ្មានការពន្យារពេលលើសពីការកំណត់

- ការពារប្រជាពលរដ្ឋ និងសហគ្រាសដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង កិច្ចការអាជីវកម្ម ដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រឆាំងនឹងការធ្វើសេចក្ដីសម្រេចទាំងឡាយណាដែលខុសឆ្គង ដែលបំពានទៅលើ ច្បាប់ និងលិខិតបទដ្ឋានជាធរមាន

- ប្រឆាំងនឹងអំពើពុករលួយរបស់មន្ត្រីរាជការ បុគ្គលិករបស់ក្រុង ស្រុក ខណ្ឌ រួមចំណែកដល់ការកសាងទំនាក់ទំនងល្អ និងធ្វើឱ្យមានទំនុកចិត្តរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ក្រុមហ៊ុន និងសហគ្រាសនានាដែលស្ថិត នៅក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

**ប្រការ៣.**

ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនត្រូវអនុវត្តដីកានេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃទី.........ខែ.............ឆ្នាំ...............

**ប្រធានក្រុមប្រឹក្សា**

(ហត្ថលេខា)

(ត្រា)

(ឈ្មោះ)

**ចំលងជូន**

- *ក្រសួងមហាផ្ទៃ*
- *ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ*
- *សាលាខេត្ត.......................*
- *គ្រប់សាលាឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌ.*

  *( ដើម្បីជូនជ្រាប )*
- *ដូចក្នុងប្រការ១ និងប្រការ៣ ( ដើម្បីអនុវត្ត )*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុង ស្រុក :........................

គណៈកម្មាធិការបោះឆ្នោត

លេខ:.................................

# កំណត់ហេតុ

## ស្តីពី

## ការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

*******

កាលពីថ្ងៃទី...........ខែ.................ឆ្នាំ................នៅ..........................................នៃសាលាក្រុង ស្រុក ខណ្ឌ. ........................................... មានបើកកិច្ចប្រជុំគណៈកម្មាធិការបោះឆ្នោត ដើម្បីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋប្រចាំក្រុង ស្រុក ខណ្ឌ.................................ក្រោមអធិបតីភាពលោក លោកស្រី.............................ប្រធានគណៈកម្មាធិការបោះឆ្នោតមូលដ្ឋាន ។

**សមាសភាពអញ្ជើញចូលរួមៈ**

- សមាជិកគណៈកម្មាធិការបោះឆ្នោត ......នាក់ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ)
- អ្នកពាក់ព័ន្ធ ......នាក់ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ)
- អ្នកសង្កេតការណ៍ ......នាក់ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ)

**អវត្តមានៈ**

១-លោក លោកស្រី................................ ជា............................................................

២- លោក លោកស្រី................................ ជា............................................................

ជាកិច្ចចាប់ផ្តើមលោក...........................................ប្រធានគណៈកម្មាធិការបោះឆ្នោត និងជាអធិបតីនៃកិច្ចប្រជុំ បន្ទាប់ពីបានពិនិត្យឃើញថាមានកូរ៉ុមគ្រប់គ្រាន់ហើយ បានមានមតិបើកអង្គប្រជុំ និងបានជំរាបជូនអង្គប្រជុំលើបញ្ហាសំខាន់ៗ ដូចខាងក្រោមៈ

- នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- បង្ហាញ និងណែនាំអំពីលក្ខណៈនៃសន្លឹកឆ្នោត
- របៀបគូសសន្លឹកឆ្នោត
- អានឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជូនអង្គប្រជុំ

បន្ទាប់មកប្រធានអង្គប្រជុំ បានប្រគល់ភារកិច្ចជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោត ដើម្បីចែកជូននូវសន្លឹកឆ្នោតម្នាក់មួយសន្លឹកៗ ជូនសមាជិក សមាជិកានៃគណៈកម្មាធិការ ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសយកបេក្ខជនដែលខ្លួនគាំទ្រ ។ ការបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយភាពស្ងៀមស្ងាត់ ត្រឹមត្រូវតាមនីតិវិធី និងគោលការណ៍ និងប្រកបដោយយុត្តិធម៌ ។

បេក្ខជនឈរឈ្មោះជាប្រធានការិយាល័យប្រជាពលរដ្ឋរួមមាន...........រូប ដូចមានបញ្ជីរាយឈ្មោះខាងក្រោម៖

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | អាយុ | មុខងារបច្ចុប្បន្ន | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |

**លទ្ធផលនៃការបោះឆ្នោត ៖**

ក្រោយពីការបោះឆ្នោតបានចប់សព្វគ្រប់តាមនីតិវិធី និងគោលការណ៍ណែនាំរួចហើយ លេខាធិការដ្ឋានបានរាយការណ៍ជូនអង្គប្រជុំដូចខាងក្រោម ៖

- សន្លឹកឆ្នោតដែលបានបោះសរុបចំនួន.......................... សន្លឹក
- សន្លឹកឆ្នោតបានការចំនួន.........................................សន្លឹក
- សន្លឹកឆ្នោតមិនបានការចំនួន....................................សន្លឹក

លទ្ធផលមានដូចតទៅ៖

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | អាយុ | មុខងារបច្ចុប្បន្ន | សម្លេងគាំទ្រ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |

ក្រោយពីរាយការណ៍ជូនអង្គប្រជុំរួចហើយ ប្រធានអង្គប្រជុំបានប្រកាសលទ្ធផលនៃការបោះឆ្នោត ដោយលោក លោកស្រី...................................ត្រូវបានជាប់ឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ ក្នុងអាណត្តិ៥ឆ្នាំ ពីឆ្នាំ ............. ដល់ឆ្នាំ........................................ ។

អង្គប្រជុំបានបញ្ចប់ជាស្ថាពរ នៅវេលាម៉ោង............. នាថ្ងៃខែឆ្នាំ...........ក្រោមបរិយាកាសស្និទស្នាលបំផុត។

ធ្វើនៅ..............ថ្ងៃទី......ខែ...........ឆ្នាំ..............

**លេខាកត់ត្រា**

បានឃើញ និងឯកភាព

ថ្ងៃទី......ខែ.......ឆ្នាំ.........

**ប្រធានអង្គប្រជុំ**

# គំរូសន្លឹកឆ្នោត






| ល.រ | ឈ្មោះបេក្ខជន | ភេទ | អាយុ | បោះឆ្នោតគាំទ្រ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |


ត្រារដ្ឋបាល
ក្រុង ស្រុក ខណ្ឌ
សន្លឹកឆ្នោត

# សេចក្តីណែនាំ

## ស្តីពីនីតិវិធី

## នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

## នៅក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ០០២ សណ៨

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០

# សេចក្ដីណែនាំ
## ស្ដីពី
## នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ នៅក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ

ផ្អែកតាមសេចក្ដីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ ស្រុក ខណ្ឌ និងប្រកាសលេខ ៩២៧ ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋ នៅសាលាក្រុង សាលាស្រុក សាលាខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ បានតម្រូវឱ្យបង្កើតការិយាល័យប្រជាពលរដ្ឋ។ ការិយាល័យប្រជាពលរដ្ឋ ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រឹតក្នុងការទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយពាក្យបណ្ដឹងទាំងនោះ ។ ការិយាល័យប្រជាពលរដ្ឋ ត្រូវមានប្រធានការិយាល័យមួយ(០១)រូប ដែលជាតំណាងអព្យាក្រឹតរបស់ប្រជាពលរដ្ឋ។ តំណាងប្រជាពលរដ្ឋនេះ ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោត ដោយគណៈកម្មាធិការបោះឆ្នោតមួយ ។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋនេះ បានដំណើរការទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងមហាផ្ទៃ សូមធ្វើសេចក្ដីណែនាំអំពីការរៀបចំគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ និងនីតិវិធីនៃការបោះឆ្នោតដែលជាបន្តទៅនេះហៅថាគណៈកម្មាធិការបោះឆ្នោត ដូចតទៅ :

### ក. អំពីការរៀបចំគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ មានសមាសភាពដូចខាងក្រោម:

- ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាប្រធាន
- សមាជិកទាំងអស់ នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាសមាជិក
- សមាជិកបី(០៣) រូប ជាតំណាងសហគមន៍ពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ ជាសមាជិក
- សមាជិកបី(០៣) រូប ជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ

ដែលបានចុះបញ្ជីត្រឹមត្រូវ ហើយដែលបានធ្វើសកម្មភាពក្នុងមូលដ្ឋានក្រុង ស្រុក ខណ្ឌ ជាសមាជិក ។

ការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានអោយគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

គណៈកម្មាធិការនេះ ត្រូវបង្កើតឡើងដោយដីការបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ដូចមានគំរូជូនភ្ជាប់ ។កជាមួយ ។

**៍.១ : ការជ្រើសរើសតំណាងពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ**

**៍.១.១: ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងពាណិជ្ជករ**

ក្នុងការជ្រើសរើសនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញតំណាង ពាណិជ្ជករតាមប្រភេទអាជីវកម្មទាំងអស់ដែលកំពុងប្រកបមុខរបរនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ។ ុងការអញ្ជើញតំណាងពាណិជ្ជករ ត្រូវគិតគូរពីចំនួនសមស្របដោយកំណត់យកចំនួនប្រមាណពី២០-៤០នាក់នៃតំណាង ពាណិជ្ជករដែលត្រូវចូលរួមស្តាប់ការផ្សព្វផ្សាយនេះ ។ ចំពោះក្រុង ស្រុក ខណ្ឌណា ដែលមានការបង្កើតជាក្រុម ឬសមាគម ឬ សហគមន៍ ឬសហករណ៍ ឬសហជីព...តាមប្រភេទអាជីវកម្មនីមួយៗ គួរអញ្ជើញតំណាងទាំងនោះមកចូលរួមតែម្តង ។

ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាអធិបតីនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ តាមរបៀបវារៈសំខាន់ៗ ចខាងក្រោម :

- ការបង្ហាញដោយសង្ខេបអំពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រួមទាំងតួនាទីសំខាន់ៗរបស់ការិយាល័យទាំងពីរនេះ
- ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ សមាសភាព និង តួនាទីសំខាន់ៗរបស់គណៈកម្មាធិការ
- នីតិវិធីបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមជាសមាជិករបស់ គណៈកម្មាធិការបោះឆ្នោត
- បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

ក្នុងកិច្ចប្រជុំខាងលើនេះ ត្រូវធ្វើការពិភាក្សាគ្នា ដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសតំណាង ណិជ្ជករ ដើម្បីចូលរួមជាសមាជិករបស់គណៈកម្មាធិការបោះឆ្នោត ។

**.១.២: ការបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជករ**

ក្នុងការបោះឆ្នោតនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌធ្វើការអញ្ជើញតំណាង ណិជ្ជករតាមប្រភេទអាជីវកម្ម ដែលបានអញ្ជើញចូលរួមស្តាប់ការផ្សព្វផ្សាយស្តីពីការជ្រើសរើសប្រធានការិយាល័យ ជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ដើម្បីចូលរួមបោះឆ្នោតជ្រើសរើស ណាងរបស់ខ្លួនឱ្យចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោត តាមកម្មវិធីដែលបានកំណត់ (មានតែតំណាងពាណិជ្ជករដែល នអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបោះឆ្នោតនេះប៉ុណ្ណោះដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងពាណិជ្ជកររបស់ខ្លួន) ។

ដូចបានបញ្ជាក់ជូនខាងលើ តំណាងពាណិជ្ជករដែលត្រូវជ្រើសរើសចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោតមានចំនួនបី (០៣) រូប។ ដើម្បីជ្រើសរើសបាននូវតំណាងទាំង០៣រូបនេះ ប្រធានក្រុមប្រឹក្សាដែលជាអធិបតីនៃកិច្ចប្រជុំត្រូវធ្វើការសម្របសម្រួលកំណត់អ្នកឈរឈ្មោះបោះឆ្នោតតាមជំរើសណាមួយដូចខាងក្រោម :

**ជំរើសទី១ :**

ត្រូវធ្វើការពិភាក្សា និងជំរុញលើកទឹកចិត្តដល់ពាណិជ្ជករទាំងអស់ដែលបានចូលរួមបោះឆ្នោតឱ្យស្ម័គ្រចិត្តឈរឈ្មោះជាបេក្ខជន យ៉ាងហោចណាស់ឱ្យបានចំនួន ៦ នាក់។ បន្ទាប់មកត្រូវធ្វើការកត់ឈ្មោះបេក្ខជន និងប្រភេទអាជីវកម្មដើម្បីធ្វើការបោះឆ្នោត។ វិធីសាស្ត្រកំណត់បេក្ខជនស្ម័គ្រចិត្តនេះអាចធ្វើឡើងតាមរយៈការលើកដៃ ឬការលើកសំនូរបំផុសគំនិត និងសាកសួរសមាជិកចូលរួមឱ្យកំណត់អ្នកដែលគួរឈរឈ្មោះជាបេក្ខជន ឬក៏វិធីសាស្ត្រផ្សេងទៀតដែលសមស្រប។

**ជំរើសទី២ :**

តំណាងពាណិជ្ជករទាំងអស់ដែលបានចូលរួមបោះឆ្នោត គឺជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

កិច្ចប្រជុំបោះឆ្នោត ត្រូវស្ថិតក្រោមការសម្របសម្រួល និងដឹកនាំដោយប្រធានក្រុមប្រឹក្សា ហើយត្រូវធានាឱ្យមានការរៀបចំឧបករណ៍ សម្ភារៈចាំបាច់នានាសម្រាប់ដំណើរការបោះឆ្នោតដូចជា ប្រអប់ដាក់សន្លឹកឆ្នោត ក្រដាសបោះឆ្នោត ក្រដាសផ្ទាំងធំ ក៏ដូចជាការរក្សារបៀបរៀបរយនៃការបោះឆ្នោតជាដើម ។

សកម្មភាពសំខាន់ៗក្នុងដំណើរការបោះឆ្នោតរួមមាន :

- កត់ឈ្មោះបេក្ខជន ឬតំណាងពាណិជ្ជករទាំងអស់ដែលបានចូលរួមជាបេក្ខជនឈរឈ្មោះបោះឆ្នោតនៅលើក្រដាសផ្ទាំងធំ (ក្រដាសផ្ទាំងធំ) ដោយរៀបតាមលំដាប់លេខរៀង និងបិតលើជញ្ជាំង ឬក្ដារខៀនដើម្បីឱ្យអ្នកចូលរួមទាំងអស់អាចមើលឃើញច្បាស់ និងងាយស្រួលក្នុងការជ្រើសរើស។ ទម្រង់សម្រាប់កត់ត្រានេះមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។
- មុននឹងចាប់ផ្ដើមធ្វើការបោះឆ្នោត អ្នកសម្របសម្រួល ត្រូវធ្វើការរំលឹកឡើងវិញពីនីតិវិធីនៃការបោះឆ្នោតដូចជាជ្រើសរើសយកតំណាងបីរូប ហើយសមាជិកនីមួយៗមានសិទ្ធិជ្រើសរើសតំណាងពាណិជ្ជករចំនួនបីរូបដែលខ្លួនពេញចិត្តជាដើម ។
- អ្នកសម្របសម្រួល ធ្វើការណែនាំដល់អ្នកចូលរួមពីការជ្រើសរើសតំណាងពាណិជ្ជករចំនួនបីរូប ដែលខ្លួនពេញចិត្ត ដោយសរសេរឱ្យបានច្បាស់លាស់ :
  - សរសេរលេខរៀងបេក្ខជនដូចមានក្នុងក្រដាសផ្ទាំងធំដែលបិតនៅលើជញ្ជាំង ឬក្ដារខៀន ឬ
  - សរសេរឈ្មោះបេក្ខជន ឬ
  - សរសេរលេខរៀង និងឈ្មោះបេក្ខជន ។

  ក្នុងការជ្រើសរើសនេះ អ្នកសម្របសម្រួល ត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ដល់អ្នកចូលរួមទាំងអស់ដើម្បីធ្វើការពិចារណា និងសម្រេចចិត្ត និងធានាថាជាការបោះឆ្នោតសម្ងាត់ និងប្រកបដោយតម្លាភាព។

- បន្ទាប់មកអ្នកសម្របសម្រួល ត្រូវអញ្ជើញអ្នកចូលរួមទាំងអស់ (ម្តងម្នាក់) មកទទួលយកសន្លឹកឆ្នោត និងធ្វើការបោះឆ្នោតនៅទីតាំងមួយដែលបានរៀបចំដាច់ដោយឡែក ដើម្បីធានាភាពសម្ងាត់ (បន្ទប់បោះឆ្នោត ឬ ទីតាំងសមស្របសម្រាប់គូសសន្លឹកឆ្នោត)។ សន្លឹកឆ្នោត ដែលបានគូសរួចហើយត្រូវយកទៅដាក់នៅក្នុងហិបឆ្នោតដែលនៅក្បែរនោះ រួចត្រឡប់ មកអង្គុយនៅកន្លែងវិញ ដើម្បីរង់ចាំស្តាប់លទ្ធផល។ សន្លឹកឆ្នោតត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំសមស្របដូចគ្នា និងមានបោះត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ។
- អ្នកសម្របសម្រួល ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតភ្លាម ដោយធ្វើការរាប់សន្លឹកឆ្នោតម្តងមួយសន្លឹកនៅមុខអ្នកចូលរួមទាំងអស់ និងធ្វើការបូកសរុបសម្លេងគាំទ្ររបស់តំណាងពាណិជ្ជករនីមួយៗ។ បន្ទាប់មក ត្រូវធ្វើចំណាត់ថ្នាក់បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ លំដាប់ទី១ លំដាប់ទី២ និងលំដាប់ទី៣ ដើម្បីជ្រើសរើសជាតំណាងពាណិជ្ជករដែលត្រូវចូលរួមក្នុងគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីមានសម្លេងគាំទ្រស្មើគ្នា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម:
  - បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី បេក្ខជនជាស្ត្រីត្រូវជាប់ឆ្នោត។
  - បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងច្រើននាក់ជាស្ត្រី ប្រធានក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាម ក្នុងចំណោមបេក្ខជនជាស្ត្រីដែលមានសម្លេងស្មើគ្នានោះ។
  - បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះសុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី ប្រធានក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតភ្លាមជាលើកទី២ ឬលើកទី៣... ជាបន្តបន្ទាប់ ដោយយកតំណាងបេក្ខជនដែលមានសម្លេងស្មើគ្នានោះមកធ្វើការបោះឆ្នោត និងប្រើប្រាស់នីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ
- នៅចុងបញ្ចប់នៃការបោះឆ្នោត ប្រធានក្រុមប្រឹក្សា ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោត និងប្រកាសអំពីឈ្មោះបេក្ខជន ដែលបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបោះឆ្នោត។ ប្រធានក្រុមប្រឹក្សាក៏ត្រូវធានាថារបាយការណ៍អំពីលទ្ធផលនៃការបោះឆ្នោតនោះ បានរៀបចំត្រឹមត្រូវ និងច្បាស់លាស់។

### ក.២ : ការជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ

### ក.២.១: ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល

ក្នុងការជ្រើសរើសនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញប្រធានអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលមានមូលដ្ឋាន និងធ្វើសកម្មភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ។

ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាអធិបតីនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ តាមរបៀបវារៈសំខាន់ៗ ដូចខាងក្រោម ៖

- ការបង្ហាញដោយសង្ខេបអំពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រួមទាំងតួនាទីសំខាន់ៗរបស់ការិយាល័យទាំងពីរនេះ
- ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ សមាសភាព និង តួនាទីសំខាន់ៗរបស់គណៈកម្មាធិការ
- នីតិវិធីបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមជា សមាជិករបស់គណៈកម្មាធិការបោះឆ្នោត
- បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ អធិបតីនៃកិច្ចប្រជុំ ត្រូវធ្វើការពិភាក្សាគ្នាដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស តំណាងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមជាសមាជិកនៃគណៈកម្មាធិការបោះឆ្នោត ។

### ក.២.២: ការបោះឆ្នោតជ្រើសរើសតំណាងអង្គការមិនមែនរដ្ឋាភិបាល

ក្នុងការបោះឆ្នោតនេះ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការអញ្ជើញតំណាង អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលមាន**ទីតាំងនៅក្នុងខេត្ត និងធ្វើសកម្មភាពនៅក្នុងក្រុង ស្រុក ខណ្ឌគោលដៅ** មកចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ចូលជាសមាជិកគណៈកម្មាធិការបោះឆ្នោតតាមកម្មវិធីដែលបានកំណត់ (មានតែតំណាងអង្គការមិនមែនរដ្ឋាភិបាលដែល បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបោះឆ្នោតនេះប៉ុណ្ណោះដែលមានសិទ្ធិបោះ ឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន) ។

ដូចបានបញ្ជាក់ជូនខាងលើ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវជ្រើសរើសចូលជាសមាជិកគណៈកម្មាធិការ បោះឆ្នោតមានចំនួន ០៣ រូប ហើយអង្គការនីមួយៗមានសិទ្ធិស្មើគ្នាក្នុងការឈរឈ្មោះបោះឆ្នោត ។

កិច្ចប្រជុំបោះឆ្នោត ត្រូវស្ថិតក្រោមការសម្របសម្រួល និងដឹកនាំដោយប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយត្រូវធានាឱ្យមានការរៀបចំឧបករណ៍ សម្ភារៈចាំបាច់នានាសម្រាប់ដំណើរការបោះឆ្នោតដូចជា ប្រអប់ដាក់សន្លឹកឆ្នោត ក្រដាសបោះឆ្នោត ក្រដាសផ្ទាំងធំ ក៏ដូចជាការរក្សារបៀបរៀបរយនៃការបោះឆ្នោតជាដើម ។

សកម្មភាពសំខាន់ៗក្នុងដំណើរការបោះឆ្នោតរួមមាន ៖

- កត់ឈ្មោះអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចូលរួមបោះឆ្នោតនៅលើក្រដាសផ្ទាំងធំ ដោយ រៀបតាមលំដាប់លេខរៀង និងបិតលើជញ្ជាំង ឬក្តារខៀន ដើម្បីឱ្យអ្នកចូលរួមទាំងអស់អាចមើលឃើញ ច្បាស់ និងងាយស្រួលក្នុងការជ្រើសរើស ។ ទម្រង់សម្រាប់កត់ត្រានេះមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ។
- មុននឹងចាប់ផ្តើមធ្វើការបោះឆ្នោត អ្នកសម្របសម្រួល ត្រូវធ្វើការរំលឹកឡើងវិញពីនីតិវិធីនៃការបោះ ឆ្នោតដូចជា ជ្រើសរើសយកតំណាងបី រូប ហើយសមាជិកនីមួយៗមានសិទ្ធិជ្រើសរើសអង្គការចំនួនបី ដែលខ្លួនពេញចិត្តជាដើម ។

- អ្នកសម្របសម្រួល ធ្វើការណែនាំដល់អ្នកចូលរួមពីការជ្រើសរើសតំណាងអង្គការចំនួនបី (០៣) ដែលខ្លួនពេញចិត្ត ដោយសរសេរឱ្យបានច្បាស់លាស់ :
  - សរសេរលេខរៀងរបស់អង្គការដូចមាននៅក្នុងក្រដាសផ្ទាំងធំ ដែលបិតនៅលើជញ្ជាំង ឬ ក្ដារខៀន ឬ
  - សរសេរឈ្មោះតំណាងអង្គការ ឬ
  - សរសេរតែឈ្មោះអង្គការ ឬ
  - សរសេរលេខរៀង ឈ្មោះតំណាងអង្គការ និងឈ្មោះអង្គការ ។

  ក្នុងការជ្រើសរើសនេះ អ្នកសម្របសម្រួលត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ដល់អ្នកចូលរួមទាំងអស់ដើម្បីធ្វើការពិចារណា និងសម្រេចចិត្ត និងធានាថាជាការបោះឆ្នោតសម្ងាត់ និងប្រកបដោយតម្លាភាព។
- បន្ទាប់មក អ្នកសម្របសម្រួល ត្រូវអញ្ជើញអ្នកចូលរួមទាំងអស់(ម្តងម្នាក់) មកទទួលយកសន្លឹកឆ្នោត និងធ្វើការបោះឆ្នោតនៅបន្ទប់គូសសន្លឹកបោះឆ្នោត ឬ ទីតាំងសមស្របសម្រាប់គូសសន្លឹកឆ្នោត ដើម្បីធានាភាពសម្ងាត់។ សន្លឹកឆ្នោតដែលបានគូសរួចហើយ ត្រូវយកទៅដាក់នៅក្នុងហិបឆ្នោតដែលនៅក្បែរនោះ រួចត្រឡប់មកអង្គុយនៅកន្លែងវិញ ដើម្បីរង់ចាំស្ដាប់លទ្ធផល។ សន្លឹកឆ្នោតត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំសមស្របដូចគ្នា និងមានបោះត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- អ្នកសម្របសម្រួល ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតភ្លាមដោយធ្វើការរាប់សន្លឹកឆ្នោតម្តងមួយសន្លឹកៗនៅមុខអ្នកចូលរួមទាំងអស់ និងបូកសរុបសម្លេងគាំទ្ររបស់អង្គការនីមួយៗ។ បន្ទាប់មកត្រូវធ្វើចំណាត់ថ្នាក់អង្គការដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេលំដាប់ទី១ លំដាប់ទី២ និងលំដាប់ទី៣ ដើម្បីជ្រើសរើសជាតំណាងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីមានសម្លេងគាំទ្រស្មើគ្នា ប្រធានក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតភ្លាមជាលើកទី២ ឬលើកទី៣... ជាបន្តបន្ទាប់ ដោយយកតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលមានសម្លេងស្មើគ្នានោះមកធ្វើការបោះឆ្នោត និងប្រើប្រាស់នីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ។
- នៅចុងបញ្ចប់នៃការបោះឆ្នោត អធិបតីនៃកិច្ចប្រជុំ ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោត និងប្រកាសឈ្មោះអង្គការដែលបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបោះឆ្នោត។ ប្រធានក្រុមប្រឹក្សាត្រូវធានាថា របាយការណ៍លទ្ធផលនៃការបោះឆ្នោតនោះបានរៀបចំត្រឹមត្រូវ និងច្បាស់លាស់។

បន្ទាប់ពីជ្រើសរើសបានតំណាងពាណិជ្ជករ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំដីកា **ស្ដីពីការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ** ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខាតាមទម្រង់ដូចមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

នៅក្នុងអាណត្តិបំពេញការងាររបស់ខ្លួន ក្នុងករណីមានតំណាងសហគមន៍ពាណិជ្ជករ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាលណាមួយក្នុងចំណោមតំណាងទាំងបី (០៣) រូប នៅក្នុងគណៈកម្មាធិការបោះឆ្នោត លាឈប់ពីការងារ ឬទទួលមរណភាព តំណាងបំរុងដែលមានលេខរៀងបន្ទាប់ ត្រូវចូលបំពេញការងារជំនួសដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចេញដីកាទទួលស្គាល់សមាសភាពថ្មីនេះ ជាផ្លូវការជាថ្មី។

**ក.៣ : តួនាទី ភារកិច្ចរបស់គណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោត មានភារកិច្ច :

- រៀបចំការប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- រៀបចំសន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- ប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- លើកសំណើជូនក្រុមប្រឹក្សាពិនិត្យ និងទទួលស្គាល់បេក្ខជនជាប់ឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋ
- ពិនិត្យ តាមដានការអនុវត្តសកម្មភាពរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ

**ក.៤ : របៀបរបបធ្វើការងាររបស់គណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោត អាចរៀបចំកិច្ចប្រជុំរបស់ខ្លួនទៅតាមការចាំបាច់ តាមសំណើរបស់ប្រធានគណៈកម្មាធិការ ឬក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬតាមសំណើយ៉ាងតិចមួយភាគបីនៃសមាជិកគណៈកម្មាធិការបោះឆ្នោត។ នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវជួយគណៈកម្មាធិការក្នុងការរៀបចំរាល់កិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការ។

## ខ. បែបបទ និងនីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

គណៈកម្មាធិការបោះឆ្នោត ត្រូវបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ តាមនីតិវិធីដូចខាងក្រោម:

- កោះប្រជុំគណៈកម្មាធិការបោះឆ្នោត
- ដាក់ស្នើបេក្ខជនឈរឈ្មោះបោះឆ្នោត
- ពិនិត្យអំពីការដាក់ស្នើបេក្ខជន និងការរៀបចំសន្លឹកឆ្នោត
- កិច្ចដំណើរការបោះឆ្នោត
- ដីកាតែងតាំង

**ខ.១: ការប្រជុំគណៈកម្មាធិការបោះឆ្នោត**

ក្រោយពេលបង្កើតបានគណៈកម្មាធិការបោះឆ្នោត យ៉ាងយូរប្រាំពីរ(០៧)ថ្ងៃ គណៈកម្មាធិការនេះ ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បី:

- ប្រកាសសមាសភាពគណៈកម្មាធិការបោះឆ្នោត
- ផ្សព្វផ្សាយអំពីសេចក្តីណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
- ណែនាំអំពីនីតិវិធីនៃការដាក់ស្នើបេក្ខភាពសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោត
- កំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

ការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោតនេះ ត្រូវរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនេះ។៚

**ខ.២: ការដាក់ស្នើបេក្ខជនឈរឈ្មោះបោះឆ្នោត**

សមាជិកគ្រប់រូប នៃគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានជ្រើសរើសតំណាងប្រជាពលរដ្ឋ មានសិទ្ធិឧទ្ទេសនាមបេក្ខជនយ៉ាងច្រើនពីរ (០២) រូប សម្រាប់ជាបេក្ខជនឈរបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ។ បេក្ខជនទាំងនោះ ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចតទៅ :

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី ៣៥ ឆ្នាំ ដល់ ៦០ ឆ្នាំ
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងក្រុង ស្រុក ខណ្ឌ ដែលសាមីជនមានបំណងឈរឈ្មោះ
- មានបទពិសោធន៍ការងាររដ្ឋបាល សង្គមស៊ីវិល ឬផ្នែកឯកជន ចាប់ពី ០៥ ឆ្នាំឡើងទៅ
- មានកំរិតវប្បធម៌ចាប់ពីមធ្យមសិក្សាបឋមភូមិ ឬសញ្ញាប័ត្រមានតម្លៃស្មើ
- បេក្ខជនមិនត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធដឹកនាំណាមួយរបស់គណបក្សនយោបាយណាមួយ ឬជាបេក្ខជនរបស់គណបក្សនយោបាយណាមួយ។

**បេក្ខជនដែលគ្មានសិទ្ធិឈរឈ្មោះបោះឆ្នោត :**

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយុទ្ធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់
- ព្រះសង្ឃ ឬ បព្វជិតសាសនា
- ជនដែលតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

ក្នុងការដាក់ស្នើបេក្ខភាពបេក្ខជននេះ សមាជិកគណៈកម្មាធិការគ្រប់រូប ត្រូវធ្វើលិខិតស្នើសុំដាក់បេក្ខជនទាំងនោះទៅប្រធានគណៈកម្មាធិការបោះឆ្នោតរៀង១ខ្លួន ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបរបស់បេក្ខជននោះ ដូចមានគំរូប្រវត្តិរូបសង្ខេបជូនភ្ជាប់មកជាមួយ។ ក្នុងការដាក់ស្នើបេក្ខជនទាំងពីររូបនេះ ត្រូវមានបេក្ខជនជាស្ត្រីមួយរូប។

គណៈកម្មាធិការ ត្រូវកំណត់កាលបរិច្ឆេទឱ្យបានច្បាស់លាស់អំពីពេលវេលានៃការចាប់ផ្តើមដាក់ស្នើបេក្ខជន និងកាលបរិច្ឆេទចុងក្រោយ។ កាលបរិច្ឆេទចាប់ផ្តើមដាក់បេក្ខភាព ត្រូវចាប់ផ្តើមពីថ្ងៃបន្ទាប់ពីកិច្ចប្រជុំនេះ ហើយត្រូវបញ្ចប់យ៉ាងយូរ ១៤ថ្ងៃ បន្ទាប់ពីថ្ងៃចាប់ផ្តើម។

**ខ.៣: ការពិនិត្យបេក្ខជនដាក់ស្នើ**

នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវជួយដល់ប្រធានគណៈកម្មាធិការ ក្នុងការពិនិត្យលើបេក្ខភាពដែលបានដាក់ស្នើ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយលក្ខណសម្បត្តិបេក្ខជនដែលបានកំណត់ក្នុងចំនុច ខ.២ នៃសេចក្តីណែនាំនេះ រួចហើយត្រូវលើកយោបល់ជូនប្រធានគណៈកម្មាធិការដើម្បីពិនិត្យ និងសម្រេច ។

ក្នុងករណីដែលពិនិត្យឃើញថាមានបេក្ខជនណាមួយ ពុំមានលក្ខណៈសម្បត្តិសមស្របតាមការកំណត់ខាងលើនេះទេ ប្រធានគណៈកម្មាធិការត្រូវធ្វើលិខិតជូនដំណឹងទៅសមាជិកគណៈកម្មាធិការដែលបានដាក់ស្នើនោះវិញ ដើម្បីជូនជ្រាបជាព័ត៌មាន។

នៅពេលដល់កាលកំណត់ចុងក្រោយហើយ បើមានការដាក់ស្នើតែបេក្ខជនតិចជាងបីរូប នោះប្រធានគណៈកម្មាធិការត្រូវស្នើអោយសមាជិកដែលដាក់ស្នើនោះ ធ្វើការដាក់ស្នើបេក្ខជនបន្ថែម ឬប្រធានឧទ្ទេសនាមបេក្ខជនបន្ថែមក៏បាន។

ក្រោយពីការពិនិត្យ សម្រេចរបស់ប្រធានគណៈកម្មាធិការរួចហើយ ប្រធានត្រូវចាត់ឱ្យនាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ រៀបចំសន្លឹកឆ្នោតទៅតាមចំនួនសមាជិកគណៈកម្មាធិការបោះឆ្នោត។

**សន្លឹកឆ្នោតនីមួយៗត្រូវ :**

- ប្រើក្រដាសពណ៌ស ដែលមានទម្រង់ ទំហំដូចគ្នា ដោយសរសេរឈ្មោះបេក្ខជន ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជន (សរសេរដោយដៃ ឬម៉ាស៊ីនអង្គុលីលេខ ឬកុំព្យូទ័រ)។
- រៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកគណៈកម្មាធិការបោះឆ្នោត
- មានត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត។

(ដូចមានគំរូសន្លឹកឆ្នោតជូនភ្ជាប់មកជាមួយ)។

### ខ.៤: កិច្ចដំណើរការបោះឆ្នោត

### ខ.៤.១ : មុនប្រតិបត្តិការបោះឆ្នោត

ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវពិនិត្យមើលអំពីកូរ៉ុម (ដោយមានវត្តមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិកសរុបរបស់គណៈកម្មាធិការបោះឆ្នោត ទើបចាត់ទុកជាបានការ) និងជំរាបជូនអង្គប្រជុំអំពីគោលការណ៍ សំខាន់ៗដូចខាងក្រោមៈ

- នីតិវិធីនៃការបោះឆ្នោត
- បង្ហាញ និងណែនាំអំពីលក្ខណៈនៃសន្លឹកឆ្នោត
- របៀបគូសសន្លឹកឆ្នោត
- អានឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជូនអង្គប្រជុំបោះឆ្នោត

ការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ដែលជាលេខាធិការដ្ឋានគណៈកម្មាធិការបោះឆ្នោត មានភារកិច្ចដូចខាងក្រោម :

- រៀបចំ និងចុះបញ្ជីវត្តមានសមាជិកគណៈកម្មាធិការបោះឆ្នោត
- រៀបចំបញ្ជីឈ្មោះបេក្ខជននៅលើក្រដាសផ្ទាំងធំ ដើម្បីត្រៀមសម្រាប់កត់ត្រាលទ្ធផលបោះឆ្នោត
- ចែកជូនសន្លឹកឆ្នោតទៅសមាជិកគណៈកម្មាធិការបោះឆ្នោត
- រាប់លទ្ធផលបោះឆ្នោត
- ធ្វើកំណត់ហេតុកិច្ចប្រជុំ
- ការងារមួយចំនួនទៀត តាមការចាំបាច់។

### ខ.៤.២ : របៀបបោះឆ្នោត :

- មានតែសមាជិកគណៈកម្មាធិការបោះឆ្នោតទេ ទើបមានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ។

- សមាជិកគណៈកម្មាធិការបោះឆ្នោតគ្រប់រូបដែលមានវត្តមាន នឹងត្រូវបានចែកជូននូវសន្លឹកឆ្នោត មួយសន្លឹក
- អ្នកបោះឆ្នោតមួយរូបៗ ត្រូវគូសសញ្ញា "✓" នៅលើសន្លឹកឆ្នោត ត្រង់កូឡោន "**ការបោះឆ្នោតគាំទ្រ**" នៅជួរបន្ទាត់ខាងស្តាំនៃឈ្មោះបេក្ខជនចំនួនមួយ (០១)រូប ដែលខ្លួនគាំទ្រ រួចយកទៅដាក់នៅក្នុងហិបឆ្នោតបិទជិតមួយដែលនៅក្បែរនោះ

**ខ.៤.៣: ការរាប់សន្លឹកឆ្នោត**

លេខាធិការដ្ឋាននៃគណៈកម្មាធិការ ត្រូវបើកហិបឆ្នោត យកសន្លឹកឆ្នោតមករាប់ ដោយផ្ទៀងផ្ទាត់ជាមួយវត្តមានរបស់សមាជិកគណៈកម្មាធិការបោះឆ្នោតមូលដ្ឋានដែលបានចូលរួម។ បន្ទាប់មក ត្រូវបើកសន្លឹកឆ្នោតម្តងមួយសន្លឹកៗ ដើម្បីពិនិត្យ និងត្រូវកត់ត្រាលទ្ធផលនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំដែលមានសរសេរឈ្មោះបេក្ខជនដូចមានក្នុងសន្លឹកឆ្នោត រួចហើយធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតនោះ។

**ខ.៤.៤: សុពលភាពនៃសន្លឹកឆ្នោត**

សន្លឹកឆ្នោត ដែលត្រូវបានទទួលស្គាល់ថាបានការ ត្រូវតែជាសន្លឹកឆ្នោតដែល :

- រក្សានូវទ្រង់ទ្រាយដូចដើមរបស់សន្លឹកឆ្នោត
- មានគូសសញ្ញា (✓) នៅក្នុងកូឡោនខាងស្តាំចំពោះបេក្ខជនដែលខ្លួនគាំទ្រ

សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល:

- មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូន
- គ្មានត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គូសគាំទ្របេក្ខជនលើសពីមួយនាក់
- មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
- មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
- រហែក ឬខូច
- មានគំនូសដែលមិនអាចកំណត់បានថា ជាគាំទ្រដល់បេក្ខជនណាមួយ។

**ខ.៤.៥: លទ្ធផលនៃការបោះឆ្នោត**

ក្រោយពេលការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ជាស្ថាពរ លេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោត ត្រូវរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការបោះឆ្នោតនេះ។ បន្ទាប់មក ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតភ្លាម។ បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ គឺជាបេក្ខជនជាប់ឆ្នោតជាប្រធាន ការិយាល័យប្រជាពលរដ្ឋ។

ក្នុងករណីមានបេក្ខជនចាប់ពីពីរ(០២)រូប ទទួលបានសម្លេងគាំទ្រច្រើនជាងគេស្មើគ្នា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម :

- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី បេក្ខជនជាស្ត្រីត្រូវជាប់ឆ្នោត។

- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះម្នាក់ ឬច្រើននាក់ជាបុរស និងច្រើននាក់ជាស្ត្រី ប្រធានគណៈកម្មាធិការ ត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាម ក្នុងចំណោមបេក្ខជនជាស្ត្រីដែលមានសម្លេងស្មើគ្នានោះ តាមនីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ ។
- បើបេក្ខជនដែលមានសម្លេងស្មើគ្នានោះសុទ្ធតែជាបុរស ឬសុទ្ធតែជាស្ត្រី ប្រធានគណៈកម្មាធិការ ត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាម ក្នុងចំណោមបេក្ខជនដែលមានសម្លេងស្មើគ្នានោះ តាមនីតិវិធីដូចបានអនុវត្តនៅលើកទី១ដែរ ។

ប្រសិនបើការបោះឆ្នោតលើកទី២នេះ នៅតែទទួលបានសម្លេងគាំទ្រស្មើគ្នាទៀត សម្លេងប្រធានគណៈកម្មាធិការមានឧត្តមានុភាព ។

**ខ.៥: ការតែងតាំង**

បន្ទាប់ពីការប្រកាសលទ្ធផលរបស់ប្រធានគណៈកម្មាធិការបោះឆ្នោតរួចហើយ ប្រធានគណៈកម្មាធិការត្រូវធ្វើសំណើទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសាមី ដើម្បីដាក់ចេញនូវដីកាតែងតាំងដូចមានគំរូជូនភ្ជាប់មកជាមួយ និងរៀបចំចុះកិច្ចសន្យាជាមួយបេក្ខជនជាប់ឆ្នោតនេះ ។ សំណើត្រូវភ្ជាប់មកជាមួយនូវកំណត់ហេតុនៃកិច្ចប្រជុំ ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ឱ្យរៀបចំសេចក្តីព្រាងដីកាស្តីពីការតែងតាំងនេះ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សា

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអង្គភាព ស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

ការិយាល័យច្រកចេញចូលតែមួយ

ONE WINDOW SERVICE OFFICE









រៀបរៀង និងចងក្រងដោយ

ក្រុមគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ
ជាន់ទី១នៃអគារនាយកដ្ឋានបុគ្គលិក
និងបណ្តុះបណ្តាលវិជ្ជាជីវៈក្រសួងមហាផ្ទៃ
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៧២៦ ៨៦១,២២០ ៩៣៥
Email: info@owso.gov.kh, Website:
www.owso.gov.kh

គាំទ្រដោយ

រាជរដ្ឋាភិបាលកម្ពុជា

ធនាគារពិភពលោក